# ក្រមសីលធម៌របស់អង្គការវេទិកាសេវាសន្តិភាពស៊ីវិល

(Code of Conduct of Forum Civil Peace Service- formZFD)

## អារម្ភកថា និងគោលបំណង (Introduction and Purpose)

ដើម្បីថែរក្សានូវគុណតម្លៃ និងស្របតាមបេសកកម្មរបស់ខ្លួន អង្គការវេទិកាសេវាសន្តិភាពស៊ីវិល (forumZFD) មានការប្តេជ្ញាចិត្តខ្ពស់ រក្សាឱ្យបានខ្ជាប់ខ្ជួនបំផុតក្នុងការអនុវត្តក្រមសីលធម៌ចំពោះបុគ្គលិកទាំងអស់របស់យើង។ ក្រមសីលធម៌ (CoC) នេះធ្វើឡើងដោយផ្អែកទៅលើគោលការណ៍ និងតម្លៃរួម ដែលបានចែងនៅក្នុងលក្ខន្តិកៈ និងបេសកកម្មរបស់អង្គការ forumZFD ។

គោលបំណងនៃក្រមសីលធម៌(CoC)នេះ បង្កើតការស្វែងយល់រួមគ្នា នៃគោលការណ៍ និងវិន័យ ក្នុងការអនុវត្តការងាររបស់បុគ្គលិកអង្គការ forumZFD ដើម្បីជម្រុញឱ្យមានបទដ្ឋានសង្គតភាព នៃឥរិយាបថបុគ្គលិកទាំងអស់។ វាគឺជាមូលដ្ឋាននៃគោលការណ៍ និងវិន័យ សម្រាប់ការអនុវត្តប្រកបដោយក្រមសីលធម៌ បទដ្ឋានសង្គម និង ច្បាប់។ វាត្រូវបានបង្កើតឡើងដើម្បីណែនាំ និងការពាររាល់បុគ្គលទាំងឡាយ ដែលធ្វើការជាមួយអង្គការ forumZFD ដោយការដាក់ចេញនូវអ្វីដែលជាការអនុវត្តប្រកបដោយវិជ្ជាជីវៈ និងសីលធម៌។

ក្រមសីលធម៌(CoC)នេះ បង្កើតឡើងដើម្បីជាសេចក្តីណែនាំ តែវាមិនអាចគ្របដណ្តប់លើរាល់ព្រឹត្តិការណ៍ដែលបុគ្គលិកអាចនឹងប្រឈមនោះទេ។ ចំពោះព្រឹត្តិការណ៍ណាដែលនាំឱ្យបុគ្គលិកសង្ស័យថា វាស្ថិតនៅក្រោមក្រមសីលធម៌នេះ នោះពួកគេអាចពិភាក្សាតាមរយៈប្រព័ន្ធរាយការណ៍ជាសម្ងាត់ដែលបានទទួលស្គាល់ដោយអង្គការដូចជា តាមរយៈអ្នកគ្រប់គ្រងផ្ទាល់(Line Manager) បុគ្គលិកចាត់តាំងរបស់ The General Equal Treatment Act (AGG)[១] ក្រុមប្រឹក្សាការងារ និងអ្នកតំណាងបុគ្គលិក(Representation of Interest-RI)។

## វិសាលភាព (Scope)

ក្រមសីលធម៌ (CoC) នេះ គឺត្រូវអនុវត្តចំពោះបុគ្គលិកទាំងអស់ ដោយមិនគិតពីប្រភេទនៃកិច្ចសន្យាការងារ ទំនួលខុសត្រូវ និងទីកន្លែងធ្វើការនោះទេ។ ក្រមសីលធម៌ (CoC) នេះ គឺមានវិសាលភាពអនុវត្តន៍ទាំងបុគ្គលិកក្នុងស្រុក និងបុគ្គលិក

[១] *The General Equal Treatment Act (AGG) គឺជាប្រព័ន្ធច្បាប់របស់ប្រទេសអាល្លឺម៉ង់ដែលមានគោលបំណងក្នុងការការពារនិងកាត់បន្ថយនូវការរើសអើងអំពី ជាតិសាសន៍ ជនជាតិ ភេទ សាសនា ជំនឿ ពិការភាព អាយុ ឬក៏ការកំណត់សំគាល់ផ្លូវភេទណាមួយ។ ដើម្បីសំរេចគោលដៅនេះ ជនរងគ្រោះនឹងត្រូវបានទទួលការការពារដោយច្បាប់ ព្រមទាំងបានភ្ជាប់ជាមួយនូវការទាមទារសំណងតាមផ្លូវច្បាប់ ទៅកាន់និយោជកនិងបុគ្គលផ្ទាល់ប្រសិនបើពួកគេបានរំលោភបំពាននូវការហាមឃាត់របស់ច្បាប់នៃការរើសអើង ។*



forumZFD - Forum Civil Peace Service - SAYON Building # 42, 2nd floor, Samdach Pan street (214), Khan Daun Penh, Phnom Penh, Cambodia-
Phone: +855 (0) 78- 377- 937- E-mail: cambodia@forumZFD.de - Website: cambodia.forumzfd.org

អន្តរជាតិ ពេញម៉ោង និងមិនពេញម៉ោង បុគ្គលិកបណ្តោះអាសន្ន និងបុគ្គលិកអចិន្ត្រៃយ៍ ព្រមទាំងអ្នកធ្វើការស្ម័គ្រចិត្ត អ្នកហាត់ការ អ្នកប្រឹក្សាយោបល់ និងអ្នកប្រឹក្សាឯករាជ្យ ដែលកំពុងបម្រើការងារឱ្យអង្គការ forumZFD។

សម្រាប់គោលដៅនៃក្រមសីលធម៌ (CoC) នេះ រាល់បុគ្គលទាំងអស់ ដែលបានរៀបរាប់ខាងលើ ត្រូវតំណាងដោយពាក្យថា "**បុគ្គលិក**"។

សមាជិកនៃក្រុមប្រឹក្សាភិបាលគ្រប់គ្រង និងក្រុមប្រឹក្សាប្រតិបត្តិ Members of the Association's bodies (Supervisory Board and Executive Board) of forumZFD ក៏ដូចជាថ្នាក់គ្រប់គ្រងទាំងអស់របស់ forumZFD liability company(GmbH) និង forumZFD foundation's Executive Board ក៏ត្រូវអនុវត្តតាមក្រមសីលធម៌ (CoC) នេះដែរ។

ក្រមសីលធម៌ (CoC) របស់អង្គការ forumZFD នេះត្រូវអនុវត្តជាលក្ខណៈសកល។

ដោយសារតែអង្គការ forumZFD ជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលយល់ពីភាពខុសគ្នានៃវប្បធម៌ និងច្បាប់ក្នុងស្រុក ដូច្នេះក្រមសីលធម៌ (CoC) នេះត្រូវបានសរសេរឡើងដោយស្របទៅតាមស្តង់ដារអន្តរជាតិ។ បុគ្គលិកអង្គការ forumZFD មានកាតព្វកិច្ចក្នុងការអនុវត្តស្របតាមច្បាប់ក្នុងស្រុកដែលមានជាធរមាន។ ប្រសិនបើច្បាប់ក្នុងស្រុកដែលបុគ្គលិកកំពុងបំពេញការងារនោះ បានកំណត់កាតព្វកិច្ចតឹងរឹងជាងក្រមសីលធម៌ (CoC)នេះ នោះច្បាប់ក្នុងស្រុកនឹងមានអនុភាពធំជាងក្នុងការអនុវត្ត។

ក្រមសីលធម៌នេះ ក៏មានវិសាលភាពចំពោះបុគ្គលិកដែលកំពុងមានភារកិច្ចនៅក្រៅកន្លែងធ្វើការ និងក្រៅម៉ោងធ្វើការ ប្រសិនបើកិច្ចការនោះបង្កើតឱ្យមានទំនាក់ទំនងរវាងបុគ្គលិក និងអង្គការ forumZFD។

សម្រាប់ករណីដោយឡែក ក្រមសីលធម៌ (CoC) នេះ ក៏អាចត្រូវបានយកមកបំពេញបន្ថែមនូវលក្ខខណ្ឌចាំបាច់ មួយចំនួនអនុលោមទៅតាមបរិបទក្នុងស្រុក។ ការដាក់បន្ថែមនេះគឺត្រូវរៀបរាប់ក្នុងឧបសម្ព័ន្ធ (Annexes) ដោយមានការដាក់ជូនក្រុមប្រឹក្សាប្រតិបត្តិ (Executive Board) ដើម្បីធ្វើការពិនិត្យ និងអនុម័តមុននឹងយកមកអនុវត្ត។

**ការអនុវត្ត (Implementation)**

ក្រមសីលធម៌ (CoC) របស់អង្គការ forumZFD នេះត្រូវបានចាត់ទុកថា ជាផ្នែកមួយនៃកិច្ចសន្យាការងារ ឬលក្ខខណ្ឌនៃសេវាកម្មដែលគិតប្រាក់កម្រៃ។ ក្រមសីលធម៌នេះនឹងត្រូវប្រគល់ និងពន្យល់ទៅដល់គ្រប់បុគ្គលិកទាំងអស់មុននឹងចាប់ផ្តើមការងារ។

បុគ្គលិកទាំងអស់ត្រូវទទួលស្គាល់ជាលាយលក្ខណ៍អក្សរ ថាពិតជាបានអាន និងយល់អំពីក្រមសីលធម៌ (CoC) នេះ ព្រមទាំងគោរពតាមអត្ថន័យនៃគោលការណ៍ទាំងឡាយនៅក្នុងក្រមសីលធម៌(CoC)នេះ ហើយយល់ស្របថា ការអនុវត្តតាមគោលការណ៍ទាំងឡាយនៅក្នុងក្រមសីលធម៌ (CoC) នេះ គឺជាផ្នែកដ៏ចាំបាច់មួយនៃលក្ខខណ្ឌការងាររបស់ពួកគេផងដែរ ។

ផ្នែកធនធានមនុស្សមានទំនួលខុសត្រូវឱ្យប្រាកដថាក្រមសីលធម៌ (CoC) នេះ គឺត្រូវបានអនុវត្ត មានការត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំ។ គណៈគ្រប់គ្រងនៃអង្គការ forumZFD ត្រូវធ្វើខ្លួនជាគំរូ ដោយគោរពតាមក្រមសីលធម៌ (CoC) និងធ្វើការអនុវត្តឱ្យបានខ្ជាប់ខ្ជួន។ នៅការិយាល័យកណ្ដាល (Head Office) អ្នកគ្រប់គ្រងទាំងអស់ត្រូវប្រាកដថា បុគ្គលិករបស់ពួកគេបានយល់ពីអត្ថន័យ និងចុះហត្ថលេខាលើក្រមសីលធម៌ (CoC) នេះ នៅតាមគ្រប់ការិយាល័យកម្មវិធីប្រចាំប្រទេស (Programs) ដែលនេះគឺជាកិច្ចការរបស់នាយកតាមតំបន់ ឬប្រទេសនីមួយៗ។

ក្រមសីលធម៌ (CoC) ជាឯកសារសាធារណៈ។ រាល់ដៃគូសហការទាំងអស់របស់អង្គការ forumZFD នឹងត្រូវបានផ្ដល់ដំណឹងស្ដីពីក្រមសីលធម៌ (CoC) នេះ នៅពេលដែលចុះកិច្ចព្រមព្រៀងលើអនុស្សារណៈនៃការយោគយល់គ្នា (Memorandum of Understanding-MoU)។

## **ក្រមសីលធម៌** ( Code of Conduct )

## **គោលការណ៍នៃការអនុវត្ត ក្រមសីលធម៌ របស់អង្គការ** Forum Civil Peace Service ( forum ZFD )

### ១. ការប្រកាន់ខ្ជាប់នូវសន្តិភាព និងអហិង្សា ( Committed to Peace and non-violence )

ខ្ញុំសូមធានាថា ការអនុវត្តការងាររបស់ខ្ញុំ គឺមានភាពស្របគ្នាជាមួយនិងគោលការណ៍នៃតម្លៃរបស់អង្គការ forumZFD ( forumZFD's values )។ ខ្ញុំនឹងធ្វើការគោរពសិទ្ធិមនុស្ស ( human rights ) និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ( human dignity ) ព្រមទាំងអនុវត្តដោយផ្អែកលើមូលដ្ឋានគ្រឹះនៃអហិង្សា។

តាមរយៈទង្វើ និងអាកប្បកិរិយា ខ្ញុំនឹងប្រកាន់គោលការណ៍នៃភាពស្មើភាពគ្នារវាងភេទទាំងពីរ ( gender equality ), ការរួមបញ្ចូលគ្នា( inclusivity ), យុត្តិធម៌សង្គម( social justice ) និងសាមគ្គីភាព( solidarity )។ ខ្ញុំយល់ដឹងថាអំពើហិង្សា និងសង្គ្រាមមិនត្រូវគ្នាជាមួយនិងតម្លៃរបស់អង្គការឡើយ ដូច្នេះហើយខ្ញុំនឹងមិនប្រព្រឹត្តនូវទង្វើដែលប្រាសចាកអំពីតម្លៃទាំងនេះឡើយ។

ខ្ញុំនឹងព្យាយាមធ្វើឱ្យល្អបំផុតក្នុងការរក្សាការពារបរិស្ថាន និងអនុវត្តប្រកបដោយនិរន្តរភាព។

<u>ការលើកកម្ពស់ ការស្ថាបនា ការបំប្លែងទំនាស់តាមបែបអហិង្សា ( Promotion of constructive non-violent conflict transformation )</u>

ក្នុងនាមជានិយោជិតនៃអង្គការ forumZFD ខ្ញុំសូមប្តេជ្ញាក្នុងការអនុវត្តការបំប្លែងទំនាស់ដោយអហិង្សា។ ខ្ញុំនឹងបដិសេធរាល់ទង្វើនៃអំពើហិង្សាដែលកើតមានចំពោះមនុស្សជាតិ និងធម្មជាតិ ហើយខ្ញុំក៏យល់ដឹងផងដែរចំពោះទង្វើណាដែលបង្កើតឱ្យមានហិង្សាក្នុងទំនាក់ទំនងសង្គម ដោយការប្រើប្រាស់ពាក្យសម្តី និងអាកប្បកិរិយាជាដើម។ ខ្ញុំចាត់ទុកជម្លោះថាវាមិនត្រឹមតែជាការរំខាននោះទេ តែវាជាផ្នែកមួយនៃការស្វែងយល់ និងជាឱកាសក្នុងការផ្លាស់ប្តូរទៅរកភាពវិជ្ជមាន។ អនុលោមតាមគោលដៅ និងគោលការណ៍របស់អង្គការ forumZFD ខ្ញុំប្តេជ្ញាថានឹងដោះស្រាយរាល់ជម្លោះផ្ទៃក្នុងទាំងអស់ដោយមានរបៀបរៀបរយ និងដោយសន្តិវិធី។

<u>ការធ្វើការជាមួយនឹងអង្គការដៃគូ ( working with partners )</u>

ការបង្កើតសន្តិភាពប្រកបដោយនិរន្តរភាព គឺត្រូវបង្កើតឡើងដោយមានការគាំទ្រពីភាគីនៃជម្លោះ។ ដូច្នេះខ្ញុំរួមជាមួយនិងអង្គការដៃគូក្នុងតំបន់នឹងធ្វើការរួមគ្នាដោយតម្លាភាព និងយុត្តិធម៌ ប្រកបដោយភាពជឿជាក់ទៅវិញទៅមក។

### ២. របៀបដែលខ្ញុំប្រព្រឹត្តចំពោះមនុស្ស ( How I treat people )

<u>គោលការណ៍នៃភាពគ្មានការរើសអើង ( Principle of non-discrimination )</u>

ក្នុងនាមជានិយោជិតនៃអង្គការ forumZFD ខ្ញុំសូមធ្វើការប្តេជ្ញាប្រកាន់ខ្ជាប់នូវតម្លៃនៃភាពចម្រុះរបស់មនុស្ស ( value of diversity ) និងគ្មានភាពរើសអើងនៅក្នុងពេលបំពេញការងាររបស់ខ្ញុំ។ ខ្ញុំនឹងគោរពសិទ្ធិនៃភាពស្មើគ្នា ជាពិសេស

ជាមួយនិងក្រុមបុគ្គលដែលងាយនឹងទទួលការប៉ះពាល់ផ្នែកផ្លូវចិត្ត។ ខ្ញុំនឹងចូលរួមចំណែកគោរពភាពស្មោះត្រង់ គុណធម៌ ភាពខុសគ្នានៃបុគ្គលម្នាក់ៗ និងភាពគ្មានការរើសអើងគ្នាក្នុងការអនុវត្តការងារដែលប្រកបដោយវិជ្ជាជីវៈនេះ។ ខ្ញុំនឹងបដិសេធរាល់ការគាំទ្រលើការរើសអើងនូវគ្រប់រូបភាព។

ខ្ញុំនឹងប្រាកដថារាល់ទំនាក់ទំនង និងអាកប្បកិរិយារបស់ខ្ញុំគឺមិនរំលោភបំពាន ឬមិនកេងប្រវ័ញ្ចអ្នកដទៃឡើយ។

ខ្ញុំនឹងគោរពសិទ្ធិបុគ្គល (people's rights) រួមទាំងសិទ្ធិកុមារ (children's rights) ផងដែរ។

ខ្ញុំនឹងចូលរួមការងារជាមួយនឹងបុគ្គលដទៃប្រកបដោយភាពប្រុងប្រយ័ត្ន និងដោយគ្មានការរើសអើងចំពោះ ជនជាតិ សង្គមជាតិ ពណ៌សម្បុរ សញ្ជាតិ សាសនា ឬគំនិត សម្លៀកបំពាក់ សកម្មភាពសហជីព វប្បធម៌ កំរិតនៃការសិក្សា ស្ថានភាពគ្រួសារ ជនដែលត្រូវការការថែទាំពិសេស អាយុ ភេទ ឬបុគ្គលដែលមានលក្ខណៈសម្គាល់ដោយឡែកណាមួយ។

ខ្ញុំនឹងវៀរចាកពីការរើសអើងគ្រប់រូបភាព ដូចជាការរំលោភបំពាន និងការធ្វើបាប កាយវិការមិនសមរម្យ អំពើហិង្សា ឬពាក្យប្រមាថមើលងាយចំពោះអ្នកដទៃ។

ការគោរពលើវប្បធម៌ និងទំនៀមទំលាប់ (Respect of Culture and Custom)

ខ្ញុំមានបំណងធ្វើការស្វែងយល់ និងគោរពតាមបទដ្ឋានវប្បធម៌នៅកន្លែងដែលអង្គការ forumZFD តាំងនៅ និងកន្លែងដែលសហការី និងសហគមន៍ ដែលខ្ញុំកំពុងធ្វើការជាមួយ ដរាបណាដែលវប្បធម៌ទាំងនោះគ្មានការបំពានលើសិទ្ធិមនុស្ស ឬអាចក្លាយជាការរើសអើងទៅលើផ្នែកណាមួយនៃប្រជាជាតិ។

## ៣.ការប្រឆាំងនឹងការរំលោភបំពាន និងការរើសអើងពូជសាសន៍ (Anti-Harassment and Anti-Racism)

អង្គការ forumZFD មិនទទួលយកឡើយនូវការរំលោភបំពានគ្រប់រូបភាព។

ការរំលោភបំពាន គឺសំដៅទៅលើរាល់ទង្វើដែលធ្វើឡើងក្នុងគោលបំណង ឬធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់បុគ្គលណាម្នាក់ និងការបង្កើតឱ្យមានភាពភិតភ័យ អរិភាព ការបង្អាប់ មើលងាយ ឬបង្កើត បរិយាកាសរំលោភបំពានណាមួយ។

អង្គការ forumZFD ចាត់ទុកការរំលោភបំពាន ដែលជាប់ទាក់ទងនឹងជាតិសាសន៍ សង្គមជាតិ ពណ៌សម្បុរ សញ្ជាតិ សាសនា ឬគំនិត សម្លៀកបំពាក់ សកម្មភាពសហជីព វប្បធម៌ កំរិតនៃការសិក្សា ស្ថានភាពគ្រួសារ ជនដែលត្រូវការការថែទាំពិសេស អាយុ ភេទ ឬបុគ្គលដែលមានលក្ខណៈសម្គាល់ដោយឡែកណាមួយជាទម្រង់នៃការរំលោភបំពាន។

ខ្ញុំនឹងមិនប្រព្រឹត្ត ឬមានឥរិយាបថរំលោភបំពាន រាល់គ្រប់រូបភាព ដោយចេតនា ឬធ្វើឲ្យនរណាម្នាក់មានអារម្មណ៍ថាមានការបៀតបៀន ងាយរងគ្រោះ ឬគ្មានអំណាចនោះឡើយ។

ខ្ញុំនឹងមិនប្រព្រឹត្តនូវការរំលោភបំពាន ឬកេងប្រវ័ញ្ចផ្លូវភេទរាល់គ្រប់រូបភាព និងមិនអាចទទួលយកបានឡើយ បើសិនជាឃើញទង្វើនេះប្រព្រឹត្តឡើងដោយសហការី។

ការរំលោភបំពានផ្លូវភេទ(sexual harassment) ត្រូវបានកំណត់ថាជាអំពើដែលបៀតបៀនផ្លូវភេទ ប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់បុគ្គល ជាទង្វើដែលមិនអនុញ្ញាត មិនអាចទទួលយកបាន មិនសមរម្យ ឬទង្វើល្មើសផ្សេងទៀតដល់ជនរងគ្រោះ

ឬការបង្កើតឱ្យមានភាពភិតភ័យ អរិភាព ភាពមិនហ្នឹងហ្ន ដោយបរិយាកាសរំលោភបំពានណាមួយ។ វាអាចកើតក្រោមរូបភាពដូចជា ការប៉ះពាល់រាងកាយ ការប្រើប្រាស់ពាក្យសម្តីដោយផ្ទាល់ ឬប្រយោល។ ក្នុងនោះដែរ ក៏រាប់បញ្ចូលទាំងការប៉ះពាល់រាងកាយដោយមិនមានការអនុញ្ញាត ឬការសំណូមពរដែលពាក់ព័ន្ធនឹងផ្លូវភេទ។

## ៤. គោលការណ៍នៃសុចរិតភាព និងកេរ្តិ៍ឈ្មោះរបស់ forumZFD (Integrity and Reputation of forumZFD)

<u>ការពារសុចរិតភាព និងកេរ្តិ៍ឈ្មោះនៃអង្គការ (Protect the integrity and reputation of the organisation)</u>

ខ្ញុំនឹងប្រកាន់ខ្ជាប់នូវគោលការណ៍នៃភាពស្មោះត្រង់ និងការពារកេរ្តិ៍ឈ្មោះរបស់អង្គការ forumZFD ដោយធានាថារាល់ទង្វើរបស់ខ្ញុំ គឺនឹងមិនប៉ះពាល់ដល់តម្លៃ និងគោលការណ៍របស់អង្គការ forumZFD ដូចមានចែងក្នុងបេសកកម្មរបស់អង្គការ forumZFD នោះទេ។

<u>ទំនាក់ទំនងសាធារណៈ និងប្រព័ន្ធផ្សព្វផ្សាយ (Public and media relations)</u>

ខ្ញុំនឹងគោរពក្រមសីលធម៌ រួមទាំងសេចក្តីណែនាំរបស់អង្គការ forumZFD ទៅលើទំនាក់ទំនងសាធារណៈ និងប្រព័ន្ធផ្សព្វផ្សាយនានា ជាពិសេសគឺនៅពេលដែលធ្វើការលើប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនងខាងក្រៅ ជួសមុខឱ្យអង្គការ forumZFD។ ខ្ញុំនឹងប្រកាន់ខ្ជាប់នូវគោលការណ៍គ្មានវិវាទ និងមិនធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់ទំនាក់ទំនងទាំងអស់។ ជាដំបូងនិងសំខាន់បំផុត ខ្ញុំនឹងមិនផ្សព្វផ្សាយព័ត៌មាន ឬយោបល់ណាមួយ ដែលអាចធ្វើឱ្យអន្តរាយដល់កេរ្តិ៍ឈ្មោះរបស់អង្គការ forumZFD និងដៃគូសហការរបស់អង្គការ forumZFD ឬធ្វើអោយប៉ះពាល់ដល់បុគ្គលិក អង្គការជាដៃគូ ឬសហគមន៍ តាមវិធីណាក៏ដោយ។

ខ្ញុំនឹងរក្សាព័ត៌មាន និងរបាយការណ៍ទាក់ទងនឹងដៃគូ សហការី ស្ថាប័នផ្តល់មូលនិធិ ឬម្ចាស់ជំនួយ ដោយការប្រុងប្រយ័ត្នខ្ពស់។ ព័ត៌មានខាងក្នុង គឺត្រូវបានចាត់ទុកថាជាព័ត៌មានសម្ងាត់ដែលមិនអនុញ្ញាតអោយចែកចាយជាសាធារណៈ។

ខ្ញុំត្រូវយកចិត្តទុកដាក់ជាពិសេស លើកាលៈទេសៈដែលអាចបង្កើតឱ្យមានវិវាទ ឯកសារសម្ងាត់ទាំងឡាយ ការដាក់ប្រកាសក្នុងប្រព័ន្ធផ្សព្វផ្សាយនានា ដែលអាចជាប់ពាក់ព័ន្ធនឹងអង្គការ។

## ៥- ដោះស្រាយទំនាស់ផលប្រយោជន៍ (Dealing with Conflict of Interest)

ទំនាស់អាចកើតឡើងរវាងផលប្រយោជន៍ផ្ទាល់ខ្លួន នឹងផលប្រយោជន៍របស់អង្គការ forumZFD ឬដៃគូសហការ និងក្រុមមនុស្សគោលដៅដែលពាក់ព័ន្ធនឹងការងាររបស់ខ្ញុំ។ ខ្ញុំនឹងមានភាពច្បាស់លាស់អំពីសក្តានុពលភាពនៃទំនាស់ផលប្រយោជន៍ (conflicts of interests) ទាំងឡាយ និងត្រូវធ្វើការជូនដំណឹង និងពិភាក្សាជាមួយអ្នកគ្រប់គ្រងផ្ទាល់របស់ខ្ញុំ។ ខ្ញុំនឹងធ្វើការដោះស្រាយប្រកបដោយភាពយោគយល់ជាមួយភាគីដែលពាក់ព័ន្ធ។

ខ្ញុំនឹងយកចិត្តទុកដាក់ចំពោះករណីដែលប្រយោជន៍បុគ្គលអាចផ្ទុយគ្នា នឹងប្រយោជន៍របស់អង្គការ forumZFD។ ក្នុងករណីមានការសង្ស័យ ខ្ញុំនឹងធ្វើការពិភាក្សាជាមួយនឹងអ្នកគ្រប់គ្រងរបស់ខ្ញុំ។

ខ្ញុំនឹងមានការប្រុងប្រយ័ត្នខ្ពស់អំពីការប្រើប្រាស់សិទ្ធិអំណាចនៅក្នុងមុខតំណែងរបស់ខ្ញុំ។ ខ្ញុំនឹងមិនបំពានតួនាទី តាមគ្រប់វិធីនៅក្នុងបរិបទនៃការងាររបស់ខ្ញុំជាមួយអង្គការ forumZFD ក៏ដូចជាដៃគូសហការរបស់យើង។

## ៦. ការរក្សាការសម្ងាត់ / ការប្រើប្រាស់ទិន្នន័យ និងចំណេះដឹង / ការប្រើប្រាស់ធនធាន ( Confidential / Use of data and knowledge / Use of resource )

ខ្ញុំនឹងមានការប្រុងប្រយ័ត្នរាល់ព័ត៌មានសម្ងាត់ ឬព័ត៌មានរសើប ( sensitive information ) ទោះជាក្នុងពេល ឬ ក្រោយពេលឈប់ធ្វើការជាមួយនឹងអង្គការ forumZFD ក៏ដោយ។ ខ្ញុំនឹងការពាររាល់ការប្រើប្រាស់ប្រព័ន្ធព័ត៌មាន និងគណនេយ្យរបស់អង្គការ forumZFD ក៏ដូចជាឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងអង្គការ forumZFD។

ព័ត៌មានដែលងាយមានផលប៉ះពាល់ ( sensitive information )តួយ៉ាងមាន៖ ព័ត៌មានផ្ទាល់ខ្លួន ព័ត៌មានអំពី ដៃគូសហការ ព័ត៌មានដែលមានបោះត្រាសម្ងាត់ ទិន្នន័យហិរញ្ញវត្ថុ កិច្ចសន្យា និង ឯកសារដែលទាក់ទងនឹងយុទ្ធសាស្ត្រ។ ប្រសិនបើមិនច្បាស់ថាព័ត៌មាននេះគឺជាព័ត៌មានសម្ងាត់ ឬយ៉ាងណានោះ ខ្ញុំត្រូវធ្វើការពិភាក្សាជាមួយនិងអ្នកគ្រប់គ្រងរបស់ខ្ញុំជាមុនសិនមុននឹងចែកចាយព័ត៌មាននោះ។

ខ្ញុំនឹងធ្វើការប្រមូល និងប្រើប្រាស់ព័ត៌មានជាពិសេសព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានសម្ងាត់ដទៃទៀត ដែលមានការអនុញ្ញាតស្របច្បាប់ និងជាតំរូវការនៅក្នុងរង្វង់ការងាររបស់អង្គការ forumZFD តែប៉ុណ្ណោះ។

ខ្ញុំនឹងប្រុងប្រយ័ត្នខ្ពស់ចំពោះប្រាក់កាស ឬទ្រព្យសម្បត្តិរបស់អង្គការ forumZFD ( ឧទាហរណ៍ដូចជា៖ យានយន្ត សម្ភារៈការិយាល័យ ទីកន្លែងស្នាក់នៅដែលផ្តល់ដោយអង្គការ forumZFD កុំព្យូទ័រ អ៊ីនធើណេត និងអ៊ីម៉ែលជាដើម )។

ខ្ញុំនឹងប្រើប្រាស់ធនធានរបស់អង្គការប្រកបដោយទំនួលខុសត្រូវខ្ពស់ និងយកចិត្តទុកដាក់ ដើម្បីឱ្យការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពចំពោះបរិស្ថាន។

ខ្ញុំនឹងមិនប្រើប្រាស់សម្ភារៈការងារដែលផ្តល់ដោយអង្គការ forumZFD សម្រាប់សកម្មភាពដែលបំពានច្បាប់ ឬបំពានក្រមសីលធម៌ (CoC) នោះទេ។ សកម្មភាពទាំងនោះរួមមាន៖ ការយាយី ការគំរាមគំហែង ឬការបំភិតបំភ័យ ការបន្ទុះបង្អាប់ ក៏ដូចជាការទុកដាក់ ប្រើប្រាស់ ដំណើរការ បញ្ជូន ចែកចាយ និងថតចម្លងផ្សេងៗដែលបង្កឲ្យមានការរើសអើង ឬរូបភាពអាសអាភាសជាដើម។

## ៧. ការផ្តល់ និងការទទួលអំណោយ / ការក្លែងបន្លំ អំពើពុករលួយ និងបក្សពួកនិយម (Giving and Accepting Gifts/ Fraud, Corruption and Nepotism )

ខ្ញុំនឹងផ្តល់ជូនអង្គការនូវវប្បធម៌នៃការជឿជាក់ ភាពស្មើភាពគ្នា និងប្រយុទ្ធប្រឆាំងអំពើពុករលួយ[២]។

ដូច្នេះខ្ញុំនឹងមិនចូលរួមរាល់សកម្មភាពពុករលួយនូវគ្រប់រូបភាព។

ខ្ញុំនឹងមិនធ្វើការផ្តល់ សន្យា ឱ្យ ឬ ទទួលសំណូកនានា រួមមានអំណោយ ឬគុណប្រយោជន៍ផ្សេងទៀតដែលជាថ្នូរទៅនឹងផលប្រយោជន៍ផ្ទាល់ខ្លួន ឬវិជ្ជាជីវៈ។ ដោយឡែកប្រសិនបើការផ្តល់ ឬទទួលអំណោយជាទំលាប់នៅក្នុងស្រុក ខ្ញុំនឹង

---

*[២] ការពុករលួយត្រូវបានអោយនិយមន័យនៅទីនេះថា "ជាការរំលោភបំពានទៅលើថាមពលនៃសេចក្តីទុកចិត្តដើម្បីកេងចំណេញផ្ទាល់ខ្លួន" ( ប្រភព Transparency International. https://www.transparency.org/en/what-is-corruption )*

ប្រាកដថាអំណោយនោះ គឺមាននៅក្នុងដែនកំណត់នៃការវិនិច្ឆ័យសមហេតុផល និងមិនលើសពីចំនួនទឹកប្រាក់សាមសិបអ៊ឺរ៉ូ 30€ ឡើយ។ ក្នុងករណីផ្សេងទៀតខ្ញុំនឹងស្វែងរកការអនុញ្ញាតពីអ្នកគ្រប់គ្រង ដែលជាអ្នកសម្រេចថាតើអំណោយនោះគួរតែប្រគល់អោយទៅអង្គការ forumZFD ឬទេ។

ខ្ញុំនឹងមិនធ្វើការដោះដូរ ឱកាសការងារ កិច្ចសន្យាការងារ ទំនិញ ឬសេវាកម្ម ជាមួយផលប្រយោជន៍ផ្លូវភេទ ឬផលប្រយោជន៍ផ្សេងៗទៀតដែលជាការប្រមាថ បន្ទុះបង្អាប់ ឬ ឥរិយាបទកេងប្រវ័ញ្ច បំពានឡើយ។

ខ្ញុំនឹងអនុវត្តរាល់ទំនាក់ទំនងរវាងបុគ្គលិក ការទិញទំនិញ និង រាល់ការប្រើប្រាស់សេវាកម្មប្រកបដោយការយកចិត្តទុកដាក់និងតម្លាភាព។

ខ្ញុំនឹងមិនធ្វើការក្លែងបន្លំ បក្សពួកនិយម ឬកិបកេង ដើម្បីទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួន ឬវិជ្ជាជីវៈឡើយ។ ខ្ញុំនឹងរាយការណ៍រាល់ការសង្ស័យ នៃអំពើក្លែងបន្លំ បក្សពួកនិយម ឬអំពើពុករលួយ តាមរយៈប្រព័ន្ធរាយការណ៍ផ្ទៃក្នុង (internal reporting system)របស់អង្គការ forumZFD ដូចដែលបានចែង។

## ៨. ការប្រើប្រាស់អាវុធ (Use of weapons)

ទោះក្នុងកាលៈទេសៈណាក៏ដោយ ខ្ញុំនឹងមិនមានជាកម្មសិទ្ធិ និងប្រើប្រាស់នូវអាវុធ ជាតិផ្ទុះ ឬ គ្រាប់រំសេវនោះឡើយ។

ខ្ញុំនឹងមិនប្រើប្រាស់ អាវុធការពារខ្លួន លើកលែងតែមានការអនុញ្ញាតពី The Board Member Programs and Qualification។

ខ្ញុំនឹងធានាថាខ្ញុំមិនមានការជាប់ទាក់ទងគ្រប់រូបភាពជាមួយនិងយោធា ឬខាងការពារសន្តិសុខផ្សេងៗ។

ខ្ញុំនឹងមិនគាំទ្ររាល់សកម្មភាពហិង្សាណាមួយដោយផ្ទាល់ ឬដោយប្រយោលក្តី។

ខ្ញុំនឹងអនុវត្តតាមគោលការណ៍ណែនាំស្តីពីសុវត្ថិភាព និងសន្តិសុខរបស់ forumZFD (Safety and Security Guideline of forumZFD) និងផែនការសន្តិសុខក្នុងតំបន់(Local Security Plan)។

## ៩. ការសេពគ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុខុសច្បាប់ (Alcohol, drug, illegal substance abuse)

ខ្ញុំនឹងមិនឋិតក្រោមឥទ្ធិពលនៃសារជាតិខុសច្បាប់នោះទេ។ ខ្ញុំនឹងមិនបើកបរយានជំនិះដោយស្ថិតក្រោមឥទ្ធិពល នៃគ្រឿងស្រវឹង ឬសារធាតុញៀនផ្សេងទៀតនោះទេ។ រាល់ការរក្សាទុក ចែកចាយ និងការប្រើប្រាស់នៃសារធាតុខុសច្បាប់នៅកន្លែងធ្វើការ គឺត្រូវបានហាមឃាត់ជាដាច់ខាត។

## ១០.ការរាយការណ៍អំពីការរំលោភបំពានលើក្រមសីលធម៌ (CoC) (Reporting Violations of the Code of Conduct)

អង្គការ forumZFD លើកទឹកចិត្តដល់បុគ្គលិករបស់ខ្លួនឱ្យផ្តល់សេចក្តីរាយការណ៍អំពីការរំលោភបំពាន ដែលគួរឱ្យសង្ស័យណាមួយនៅលើក្រមសីលធម៌ (CoC) នេះ។ គោលបំណងនៃសេចក្តីរាយការណ៍ និងការតាមដានលើការ

រំលោភបំពាន ដែលអាចនឹងកើតមាន គឺដើម្បីរក្សានូវតម្លៃ និងគោលការណ៍ទាំងឡាយនៅក្នុងក្រមសីលធម៌ (CoC) នេះ ក្នុងនោះដែរក៏ដើម្បីរក្សាការស្វែងយល់រួមគ្នា នៃគោលការណ៍ និងវប្បធម៌របស់អង្គការ forumZFD ។ សេចក្តីរាយការណ៍នៃការរំលោភបំពាន គឺអាចធ្វើឡើងតាមនីតិវិធីនៃការរាយការណ៍ផ្ទៃក្នុង (internal reporting procedure)។ ព័ត៌មានលំអិតអាចរកបាននៅក្នុងឯកសារឧបសម្ព័ន្ធ។

<u>ឯកសារយោង</u>

- Mission statement forumZFD
- Forum Civil Peace Service – Articles of association
- Guidelines: Financial responsibility, signature authority, absence cover (internal document)
- Safety and Security Risk Management Policy (SSRMP) (internal document)
- Social media guidelines for forumZFD employees in Germany and overseas (internal document)
- Code for public relations work of Forum Ziviler Friedensdienst e. V. (forumZFD) (internal document)
- Work agreement: regulation on the representation of interests of employees in the programs of forumZFD abroad (internal document)
- Procedure for complaints under the General Equal Treatment Act - Information for employees (internal document)
- Internal Reporting of Violations of the Code of Conduct of forumZFD (internal document)

## ឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងកិច្ចសន្យាការងារ

## អនុវត្តទៅតាមក្រមសីលធម៌របស់អង្គការវេទិកាសេវាសន្តិភាពស៊ីវិល ( forumZFD)

ខ្ញុំសូមបញ្ជាក់អះអាងថាក្រមសីលធម៌នេះត្រូវបានផ្តល់ឱ្យ និងបានពន្យល់មកដល់ខ្ញុំ។ ខ្ញុំបានអាន និងយល់អំពីក្រមសីលធម៌នេះ។ ខ្ញុំនឹងអនុវត្តទៅតាមច្បាប់នៃក្រមសីលធម៌នេះ ហើយខ្ញុំទទួលស្គាល់ថាការអនុវត្តតាមក្រមសីលធម៌នេះគឺជាលក្ខខណ្ឌមួយចាំបាច់សំរាប់ការចាប់ផ្តើមនិងការបន្តការងាររបស់ខ្ញុំ។

**ត្រកូល, ឈ្មោះ** ____________________________________________

______________________________ ______________________________

**ទីកន្លែង, ថ្ងៃ ខែ ឆ្នាំ** **ហត្ថលេខា**